ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥-០១៧-៤០៣ សរ.ជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកំណត់ទំហំទឹកប្រាក់សម្រាប់ការដេញថ្លៃ ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី៨

យោងតាមសេចក្តីជូនដំណឹងលេខ ធ១៣.០១៦.៨៤៣.សជណ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៦ ស្តីពីប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងដាក់ឲ្យមានការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាលើកទី៨ **នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧** ដែលមានទំហំទឹកប្រាក់ចំនួន **៤០.០០០.០០០.០០០ រៀល (សែសិបប៊ីលានរៀល)** ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបជាព័ត៌មាន និងត្រៀមលក្ខណៈចូលរួមការដេញថ្លៃតាមកាលបរិច្ឆេទខាងលើតាមការគួរ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងមកនាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា។/.

សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣/ (៨៥៥-២៣) ៧២២ ២២១ EX ១០៤៨
សារអេឡិចត្រូនិក : lpco_info@nbc.org.kh